NSW HEALTH

*ប័ណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺមេនីងហ្គោខូកខល

***មេនីងហ្គោខូកខលគឺជាជំងឺម្យ៉ាងបង្កដោយបាក់តេរីដែលអាចធ្វើឲ្យមានជំងឺធ្ងន់ធ្ងរ។ ជំងឺនេះមិនកើតមានជាទូទៅឡើយនៅក្នុងរដ្ឋ NSW ហើយកើតមានញឹកញយនៅក្នុងរដូវរងានិងរដូវផ្ការីក។ ទារក កុមារតូចៗ ក្មេងជំទង់ និងជនពេញវ័យក្មេងៗ មានគ្រោះថ្នាក់បំផុតក្នុងការកើតជំងឺនេះ។ ការព្យាបាលដើមដំបូងមានសារសំខាន់ណាស់។***

**កែតំរូវចុងក្រោយ៖** ថ្ងៃទី 17 ខែមករា ឆ្នាំ 2008

## តើមេនីងហ្គោខូកខលគឺជាជំងឺអ្វីទៅ?

- មេនីងហ្គោខូកខលគឺជាជំងឺធ្ងន់ធ្ងរមួយដែលជាធម្មតាបណ្តាលឲ្យកើតរោគរលាកស្រោមខួរក្បាល (រលាកភ្នាសខួរក្បាល និងខួរឆ្អឹងខ្នង) និង/ឬរោគពិសឈាម (ឈាមពុល)។ ទំរង់កំរនៃជំងឺនេះមានរួមទាំងរោគរលាកសន្លាក់ រលាកសួត និងរលាកសន្ធានភ្នែក (ការរលាកស្រទាប់ក្រៅនៃភ្នែកនិងត្របកភ្នែក)។
- អ្នកកើតជំងឺមេនីងហ្គោខូកខលអាចធ្លាក់ខ្លួនឈឺខ្លាំងយ៉ាងរហ័ស។ អ្នកជំងឺមេនីងហ្គោខូកខលចំនួនប្រាំទៅដប់ភាគរយបាត់បង់ជីវិត ទោះជាមានការព្យាបាលយ៉ាងលឿនក៏ដោយ។
- ជំងឺនេះមិនសូវកើតមានទេនៅក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយឥឡូវនេះរដ្ឋ NSW មានករណីជំងឺនេះប្រហែលជា 100 ទៅ 130 ក្នុងមួយឆ្នាំៗ។ រដូវរងានិងរដូវផ្ការីក គឺជាពេលកើតជំងឺមេនីងហ្គោខូកខលខ្លាំងបំផុត។
- ជំងឺមេនីងហ្គោខូកខលគឺបណ្តាលមកពីការឆ្លងបាក់តេរីមេនីងហ្គោខូកខីស ដែលមានក្រុមសេរ៉ូមមួយចំនួន។ នៅក្នុងរដ្ឋ NSW ទំរង់ទូទៅបំផុតគឺក្រុមសេរ៉ូម B ។ រដ្ឋ NSW គ្មានថ្នាំបង្ការរោគដែលមានប្រសិទ្ធភាពទប់ទល់នឹងក្រុមសេរ៉ូម B ទេ។ ក្រុមសេរ៉ូម C កំរកើតមានណាស់នៅក្នុងរដ្ឋ NSW បើប្រៀបធៀបនឹងក្រុមសេរ៉ូម B ជាពិសេសចាប់តាំងពីមានការចាក់ថ្នាំបង្ការជំងឺមេនីងហ្គោខូកខលប្រភេទ C មក។
- ចំនួនរវាងពី 5 ទៅ 25 ភាគរយនៃអ្នកជំងឺ ផ្ទុកបាក់តេរីមេនីងហ្គោខូកខលនៅទីជំរៅនៃច្រមុះនិងបំពង់ក ដោយគ្មានបង្ហាញជំងឺឬរោគសញ្ញាណាមួយឡើយ។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- រោគសញ្ញានៃជំងឺមេនីងហ្គោខូកខលគ្មានភាពជាក់លាក់ទេ ប៉ុន្តែប្រហែលជាមានរួមទាំងការកើតភ្លាមនូវគ្រុនក្តៅ ឈឺក្បាល រឹងកញ្ចឹងក ឈឺសន្លាក់ឆ្អឹង ស្នាមកន្ទួលជាំឬស្នាមជាំ មិនចូលចិត្តពន្លឺខ្លាំង ចង្អោរ និងក្អួត។
- មិនមែនរោគសញ្ញាទាំងអស់អាចកើតមានឡើងព្រមពេលគ្នានោះឡើយ។
- កុមារតូចៗអាចមានរោគសញ្ញាមិនជាក់លាក់ឡើយ។ រោគសញ្ញាទាំងនេះអាចមានរួមទាំងការមួម៉ៅ លំបាកភ្ញាក់ពីដំណេក យំសម្លេងគ្រលួច និងមិនព្រមញ៉ាំអ្វីឡើយ។
- កន្ទួលរបស់ជំងឺមេនីងហ្គោខូកខលមិនស្រកទៅវិញតាមរយៈការសង្កត់ថ្នមៗទៅលើស្បែកនោះទេ។ កន្ទួលនេះមិនកើតមានចំពោះមនុស្សទាំងអស់ដែលកើតជំងឺមេនីងហ្គោខូកខលទេ ឬមួយកន្ទួលនេះអាចកើតមាននៅពេលក្រោយមកទៀតនៅក្នុងអំឡុងពេលនៃជំងឺនេះ។

- ជួនកាលរោគសញ្ញាពិសេសអាចកើតមាននៅបន្ទាប់ពីរោគសញ្ញាមិនសូវជាក់លាក់ទាំងឡាយ ដោយមានរួមទាំងការឈឺជើង ត្រជាក់ដៃ និងស្បែកពណ៌ចម្លែក។
- ជួនកាលជំងឺមេនីងហ្គោខូកខលអាចកើតមានបន្ទាប់ពីការកើតរោគរលាកផ្លូវដង្ហើមផ្សេងទៀត។
- អ្នកដែលមានរោគសញ្ញានៃជំងឺមេនីងហ្គោខូកខល គួរទៅជួបវេជ្ជបណ្ឌិតជាបន្ទាន់ ជាពិសេសបើកើតមានដោយមិនបាត់ទៅវិញនូវគ្រុនក្ដៅ ភាពមួយម៉ៅ វិលមុខ ឬអស់កម្លាំង ឬមួយកុមារមិនទទួលទានអាហារដូចធម្មតា។

## តើជំងឺនេះឆ្លងតាមវិធីណា?

- បាក់តេរីមេនីងហ្គោខូកខលមិនឆ្លងដោយងាយស្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតទេ ហើយបាក់តេរីនេះមិនរស់រានបានល្អឡើយនៅខាងក្រៅរាងកាយមនុស្ស។
- បាក់តេរីនេះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈសារធាតុចេញពីទីជំរៅនៃច្រមុះនិងបំពង់ក។ ជាទូទៅ ការឆ្លងនេះតម្រូវឲ្យមានការប៉ះពាល់ជិតស្និទ្ធនិងយូរពេលជាមួយអ្នកផ្ទុកបាក់តេរីនេះ ដែលជាធម្មតាគ្មានជំងឺអ្វីសោះឡើយ។ ឧទាហរណ៍មួយនៃ“ការប៉ះពាល់ជិតស្និទ្ធនិងយូរពេល” គឺការរស់នៅក្នុងផ្ទះជាមួយគ្នា ឬការថើបជញ្ជក់មាត់ស្និទ្ធស្នាលខ្លាំង។
- បាក់តេរីមេនីងហ្គោខូកខលមិនឆ្លងដោយងាយស្រួលតាមរយៈការទទួលទានភេសជ្ជៈ អាហារ ឬបារីរួមគ្នាឡើយ។

## តើអ្នកណាដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

ទោះជាជំងឺនេះអាចយាយីជនរាល់រូបក្តី ក៏អ្នកដែលមានគ្រោះថ្នាក់ខ្លាំងមានរួមទាំង៖

- អ្នកនៅក្នុងផ្ទះជាមួយ ដែលប៉ះពាល់អ្នកកើតជំងឺមេនីងហ្គោខូកខល
- ទារក កុមារក្មេងខ្ចី ក្មេងជំទង់ និងជនពេញវ័យក្មេងៗ
- អ្នកដែលស្រូបផ្សែងបារី និងអ្នកដែលប៉ះនឹងអ្នកជក់បារី
- អ្នកថើបជញ្ជក់មាត់យ៉ាងស្និទ្ធស្នាលខ្លាំងជាមួយដៃគូច្រើនជាងម្នាក់
- អ្នកកើតជំងឺផ្លូវដកដង្ហើមផ្នែកខាងលើដែលបង្កដោយវីរុសនៅពេលថ្មីៗ
- អ្នកធ្វើដំណើរទៅកាន់បណ្តាប្រទេសដែលមានអត្រាខ្ពស់នូវជំងឺមេនីងហ្គោខូកខល
- អ្នកមានសរីរាង្គអណ្តើកដែលមិនដំណើរការ ឬអ្នកមានរោគកំរផ្សេងៗមួយចំនួនទៀត។

អ្នកដែលបានប៉ះពាល់តិចតួចតែប៉ុណ្ណោះជាមួយអ្នកកើតជំងឺមេនីងហ្គោខូកខល មានគ្រោះថ្នាក់តិចតួចណាស់ក្នុងការកើតជំងឺនេះ។ បុគ្គលិកថែទាំសុខភាពគ្មានគ្រោះថ្នាក់ខ្លាំងទេ លុះត្រាតែអ្នកទាំងនោះបានប៉ះពាល់សារធាតុនៃបំពង់កនិងច្រមុះ (ឧទាហរណ៍៖ បើបុគ្គលិកនោះបានធ្វើឲ្យអ្នកជំងឺមានដង្ហើមឡើងវិញតាមរយៈការផ្លុំខ្យល់តាមមាត់ ឬស៊កដាក់បំពង់ទៅក្នុងសរីរាង្គរបស់អ្នកជំងឺដោយមិនប្រើស្រោមមុខ)។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

ការឈប់ជក់បារីជួយកាត់បន្ថយគ្រោះថ្នាក់ចម្លងបាក់តេរី។ កុំជក់បារីនៅក្នុងរថយន្តនិងក្នុងផ្ទះ។

ថ្នាំបង្ការរោគមានពីរប្រភេទ។

- *ថ្នាំបង្ការរោគមេនីងហ្គោខូកខល conjugate ប្រភេទ C* ការពារទល់នឹងជំងឺមេនីងហ្គោខូកខលក្រុម C ។ ថ្នាំនេះគួរចាក់ឲ្យកុមារទាំងអស់នៅពេលមានអាយុមួយឆ្នាំ (ជាផ្នែកនៃការចាក់ថ្នាំបង្ការរោគប្រក្រតីដោយឥតគិតថ្លៃ) និងអ្នកដែលធ្លាប់កើតជំងឺមេនីងហ្គោខូកខល។
- *ថ្នាំបង្ការរោគមេនីងហ្គោខូកខល polysaccharide* ការពារទល់នឹងក្រុម A, C, Y និង W135 ។ ថ្នាំនេះគួរចាក់ឲ្យអ្នកធ្វើដំណើរទៅកាន់បណ្តាប្រទេសដែលមានការរាតត្បាតនៃជំងឺមេនីងហ្គោខូកខល (ឧទាហរណ៍៖ ផ្នែកតំបន់សាហារ៉ានៃទ្វីបអាហ្វ្រិក [sub-Saharan Africa] និងអ្នកដែលធ្វើដំណើរទៅចូលរួមពិធីបុណ្យ Hajj នៅក្នុងប្រទេសអារ៉ាប់ សាអូឌីត)។

ថ្នាំបង្ការរោគទាំងពីរនេះគួរចាក់ឲ្យបុគ្គលិកមន្ទីរពិសោធន៍ដែលធ្វើការជាមួយបណ្តាបាក់តេរីមេនីងហ្គោខូកខីស និងចាក់ឲ្យអ្នកដែលសរីរាង្គអណ្តើករបស់ខ្លួនមិនដំណើរការ ហើយមានជំងឺជាក់លាក់ផ្សេងទៀត។

ដោយសារតែថ្នាំបង្ការរោគនេះមិនការពារទល់នឹងមេនីងហ្គោខូកខលក្រុម B ដែលជាជំងឺទូទៅជាងនោះ អ្នកដែលបានចាក់ថ្នាំបង្ការរោគហើយនៅតែត្រូវមានការប្រុងប្រយ័ត្នអំពីរោគសញ្ញានិងសញ្ញាទាំងឡាយនៃជំងឺមេនីងហ្គោខូកខល។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ការវិនិច្ឆ័យរោគគឺផ្អែកទៅលើប្រវត្តិនិងការពិនិត្យអ្នកជំងឺ។ ជួនកាលការវិនិច្ឆ័យរោគមានការលំបាកនៅក្នុងដំណាក់កាលដំបូងនៃជំងឺនេះ។ ការបញ្ជាក់អំពីការកើតមានរោគនេះតម្រូវឲ្យធ្វើតេស្តសំណាកពីអ្នកជំងឺ ដោយមានរួមទាំងការធ្វើតេស្តឈាម ទឹកក្នុងស្រោមខួរក្បាលនិងខួរឆ្អឹងខ្នង ឬសំណាកស្បែក។ លទ្ធផលនៃការធ្វើតេស្តអាចត្រូវការពេលផ្សេងៗគ្នាដោយអាស្រ័យលើករណីនីមួយៗ និងប្រភេទនៃតេស្តដែលធ្វើ។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

អ្នកជំងឺមេនីងហ្គោខូកខលត្រូវការព្យាបាលជាបន្ទាន់ដោយថ្នាំអង់ទីប៊ីយោទិក ហើយជាធម្មតាការព្យាបាលត្រូវចាប់ផ្តើមនៅមុនពេលតេស្តទាំងឡាយបញ្ជាក់ថាកើតជំងឺនេះ។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

មន្ទីរពេទ្យនិងមន្ទីរពិសោធន៍រាយការណ៍ប្រាប់ផ្នែកសុខភាពសាធារណៈ (Public Health Unit - PHU) ក្នុងតំបន់ អំពីករណីនៃជំងឺមេនីងហ្គោខូកខល។ បុគ្គលិក PHU នឹងធ្វើការជាមួយវេជ្ជបណ្ឌិត អ្នកជំងឺ ឬគ្រួសារអ្នកជំងឺ ដើម្បីរកមើលដឹងអ្នកដែលបានទៅជិតអ្នកជំងឺ (ដោយផ្អែកលើរយៈពេលនិងលក្ខណៈនៃការប៉ះពាល់ អ្នកទាំងនោះត្រូវគេហៅថាអ្នកប៉ះពាល់មេរោគ)។ អ្នកប៉ះពាល់មេរោគនឹងទទួលព័ត៌មានអំពីជំងឺមេនីងហ្គោខូកខល។ ផ្នែកសុខភាពសាធារណៈនឹងរកមើលដឹងយ៉ាងម៉ត់ចត់នូវអ្នកប៉ះពាល់មេរោគជិតស្និទ្ធមួយក្រុមតូច និងផ្តល់ឲ្យអ្នកទាំងនោះនូវថ្នាំអង់ទីប៊ីយោទិកកំចាត់មេរោគនេះ ដោយសារតែអ្នកទាំងនោះទំនងជាផ្ទុកបាក់តេរីនេះ។ ថ្នាំអង់ទីប៊ីយោទិកទាំងនេះកំចាត់បាក់តេរីពីបំពង់ក និងបង្ការបាក់តេរីកុំឲ្យឆ្លងទៅកាន់អ្នកដទៃ។ ថ្នាំអង់ទីប៊ីយោទិកកំចាត់មេរោគនេះមានលក្ខណៈខុសគ្នានឹងថ្នាំអង់ទីប៊ីយោទិកដែលប្រើសំរាប់ព្យាបាលជំងឺនេះ ហើយអ្នកទទួលថ្នាំនេះនៅតែមានគ្រោះថ្នាក់ខ្លះក្នុងការកើតជំងឺនេះដែរ។ ហេតុនេះ អ្នកប៉ះពាល់មេរោគ*ទាំងអស់* គួរដឹងអំពីរោគសញ្ញានៃជំងឺមេនីងហ្គោខូកខល ហើយគួរទៅជួបវេជ្ជបណ្ឌិតជាបន្ទាន់ បើរោគសញ្ញាទាំងនេះកើតមានឡើង។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW

ដើម្បីទទួលព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិត ផ្នែកសុខភាពសាធារណៈក្នុងតំបន់ ឬមណ្ឌលសុខភាពសហគមន៍របស់លោកអ្នក។ សូមរកមើលនៅក្រោមពាក្យ *NSW Government* នៅផ្នែកខាងមុខនៃសៀវភៅទូរស័ព្ទ White Pages ។

| តំបន់ទីក្រុង | ទីតាំង | លេខទូរស័ព្ទ | តំបន់ជនបទ | ទីតាំង | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| **Northern Sydney/Central Coast** | Hornsby | 02 9477 9400 | **Greater Southern** | Goulburn | 02 4824 1837 |
| | Gosford | 02 4349 4845 | | Albury | 02 6080 8900 |
| **South Eastern Sydney/Illawarra** | Randwick | 02 9382 8333 | **Greater Western** | Broken Hill | 08 8080 1499 |
| | Wollongong | 02 4221 6700 | | Dubbo | 02 6841 5569 |
| **Sydney South West** | Camperdown | 02 9515 9420 | | Bathurst | 02 6339 5601 |
| **Sydney West** | Penrith | 02 4734 2022 | **Hunter/New England** | Newcastle | 02 4924 6477 |
| | Parramatta | 02 9840 3603 | | Tamworth | 02 6767 8630 |
| **Justice Health Service** | Matraville | 02 9311 2707 | **North Coast** | Port Macquarie | 02 6588 2750 |
| **NSW Department of Health** | Nth Sydney | 02 9391 9000 | | Lismore | 02 6620 7500 |
| **NSW Health: www.health.nsw.gov.au** | | | | | |

ព័ត៌មានពេញលេញនៃផ្នែកសុខភាពសាធារណៈ មាននៅតាមវិបសៃ
www.health.nsw.gov.au/publichealth/infectious/phus.asp